YUNNAN DAILY PRESS GROUP
No.210

ប្រទេសចិន-ខេត្តយូនណាន

ភ្នំពេញប្រៃសណីយ៍

klunerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី28លេខ8137 ថ្ងៃសុក្រ ទី24 ខែមករា ឆ្នាំ2020

រសជាតិថ្មីនៃបុណ្យចូលឆ្នាំប្រពៃណីចិន

អបអរឆ្នាំថ្មីចិន យ៉ាងសប្បាយរីករាយ ដោយ ចាំង ចុំង

ជិះរថភ្លើងល្បឿន ល្បឿនទៅស្រុកកំណើតវិញ ដើម្បីឆ្លង បុណ្យចូលឆ្នាំប្រពៃណីចិន (ដោយ ស៊ីន ហួចិន)

ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០ ជាថ្ងៃដាច់ឆ្នាំតាមចន្ទគតិចិន ។ ជនជាតិចិននិងអាណិកជនចិនទូទាំងពិភពលោក នឹងរួមគ្នាអបអរសាទរបុណ្យចូលឆ្នាំប្រពៃណីចិន ។ បុណ្យចូលឆ្នាំប្រពៃណីចិនជារយៈពេលដែលក្រុមគ្រួសារជួបជុំជាមួយគ្នា ។ សព្វថ្ងៃបុណ្យចូលឆ្នាំប្រពៃណីចិនបាន និងកំពុងបង្ហាញពីការផ្លាស់ប្តូរខ្លះនៅប្រទេសចិន។

មុននិងក្រោយពេលបុណ្យចូលឆ្នាំប្រពៃណីចិននៅប្រទេសចិនមានមនុស្សធ្វើដំណើរទៅមកដែលមានចំនួនច្រើនជាងគេលើពិភពលោក ។ ប្រជាជនចិនមួយចំនួនធំត្រូវធ្វើដំណើរយ៉ាងអ្វាយ ដើម្បីទៅជួបជុំជាមួយក្រុមគ្រួសារនៅស្រុកកំណើត ។ តាមស្ថិតិមុននិងក្រោយពេលបុណ្យចូលឆ្នាំប្រពៃណីចិន២០២០ប្រព័ន្ធគមនាគមន៍ចិននឹងដឹកអ្នកដំណើរ៣០០០លាននាក់ស្មើនឹងប្រជាជនទូទាំងប្រទេសចិនធ្វើដំណើរ២ដង ។ កាលមុននៅពេលចូលឆ្នាំប្រពៃណីចិនប្រព័ន្ធគមនាគមន៍ចិនតែងតែរងសម្ពាធយ៉ាងធ្ងន់ដោយសារមានអ្នកដំណើរច្រើនពេក ។ ប៉ុន្តែទន្ទឹមនឹងការអភិវឌ្ឍ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ចិនបញ្ហា"ពិបាកទិញសំបុត្ររថភ្លើង"ត្រូវដោះស្រាយជាបន្តបន្ទាប់នៅប្រទេសចិន។ មុននឹងបុណ្យចូលឆ្នាំប្រពៃណីចិននេះ កម្មករខេត្តយូនណានជាង៦០០នាក់ដែលធ្វើការនៅខេត្តក្វាងតុងបានជិះរថភ្លើងល្បឿនលឿនឥតគិតថ្លៃដែលរួមគ្នាផ្តល់ដោយខេត្តយូនណាន និងខេត្តក្វាងតុងដើម្បីធ្វើដំណើរទៅស្រុកកំណើតវិញនៅថ្ងៃទី ១៣ខែមករា ឆ្នាំ២០២០ ។

ប៉ុន្មានឆ្នាំមកនេះក្រៅពីទៅឆ្លងបុណ្យចូលឆ្នាំប្រពៃណីចិននៅស្រុកកំណើតមានប្រជាជនចិនកាន់តែច្រើនទៅធ្វើទេសចរនៅពេលចូលឆ្នាំថ្មី។

ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីចិន២០២០ មានជនជាតិចិនកាន់តែច្រើនសម្រេចចិត្តទៅធ្វើទេសចរនៅថ្ងៃឈប់សម្រាក។ តាមរបាយការណ៍សិក្សាស្រាវជ្រាវអំពីនិន្នាការ"ទេសចរណ៍បុណ្យចូលឆ្នាំប្រពៃណីចិន ២០២០" ដែលប្រកាសដោយក្រុមហ៊ុន Ctrip បានឱ្យដឹងថា ប្រជាជនចិន៤៥០ លាននាក់នឹងទៅធ្វើទេសចរក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីចិននេះ ។ សព្វថ្ងៃជនជាតិចិនច្រើនមិនត្រឹមតែទៅធ្វើទេសចរក្នុងស្រុកនៅបុណ្យចូលឆ្នាំថ្មីប៉ុណ្ណោះទេ ហើយក៏ចូលចិត្តនៅដើរលេងនៅក្រៅប្រទេសក្នុងឱកាសនេះដែរ ។ តាមស្ថិតិពីក្រុមហ៊ុនទេសចរណ៍មួយចំនួនបានឱ្យដឹងថា ប្រទេសកម្ពុជា ថៃ សិង្ហបុរី វៀតណាម មីយ៉ាន់ម៉ា និងប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនទៀតដែលមានចម្ងាយមិនឆ្ងាយពីប្រទេសចិនហើយមានការងាយស្រួលក្នុងការស្នើសុំទិដ្ឋាការនិងមានអាកាសធាតុល្អប្រសើរនោះបានក្លាយទៅជាទីដៅទេសចរណ៍សំខាន់របស់ទេសចរចិន ។

"ការទិញទំនិញឆ្លងបុណ្យចូលឆ្នាំថ្មី"ក៏ជាទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិចិនដែរ ។ មុនពេលចូលឆ្នាំប្រពៃណីចិនក្រៅពីផ្សារសំខាន់ៗនៅខេត្តក្រុងនានាវេបសាយពាណិជ្ជកម្មអេឡិចត្រូនិកផ្សេងៗក៏បានរៀបចំ"ទិវាទំនិញឆ្លងបុណ្យចូលឆ្នាំថ្មី"ដែរ ។ ក្នុងថ្ងៃទី១នៃ"ទិវាទំនិញបុណ្យចូលឆ្នាំថ្មី២០២០ Tmall"របស់ក្រុមហ៊ុន ALIBABA ផ្តែបោមរបស់ក្រុងយូនឈឹង នៃខេត្តសានស៊ីប្រទេសចិនបានត្រូវគេទិញជា ១០០០តោន ។ គួរបញ្ជាក់ថា ប្រទេសចិនជាប្រទេសនាំចូលគ្រឿងបរិភោគច្រើនជាងគេលើពិភពលោក។តាមទិន្នន័យពីក្រុមហ៊ុនJD ប្រទេសចិនបានឱ្យដឹងថា នៅពាក់កណ្តាលទី ១ នៃខែមករាឆ្នាំ ២០២០ ចំនួនផ្លែឈើនាំ ចូលពីបរទេសដែលត្រូវគេទិញតាម វេបសាយ JD បានកើនឡើង២,២ដង ។ ផ្លែចេក ឆឺរី និងម្សៅជាផ្លែឈើនាំចូលដែលត្រូវគេទិញបានច្រើនជាងគេ ។ តាមស្ថិតិពីអាជ្ញាធរជាតិប្រៃសណីយ៍ចិនបានឱ្យដឹងថាក្នុងបុណ្យចូលឆ្នាំប្រពៃណីចិន២០១៩ កញ្ចប់ទំនិញដែលត្រូវគេផ្ញើក្នុងប្រទេសចិនមានចំនួន ១៦១០ លានកញ្ចប់ ។ ការទិញទំនិញឆ្លងបុណ្យចូលឆ្នាំថ្មីបានក្លាយទៅជារឿងដ៏សាមញ្ញក្នុងប្រទេសចិន។

ក្រៅពីនេះ នៅមានការផ្លាស់ប្តូរច្រើនដែលកំពុងកើតឡើងក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីចិនដែលជាបុណ្យប្រពៃណីរាប់ពាន់ឆ្នាំមកហើយ។

ការផ្លាស់ប្តូរនៃបុណ្យចូលឆ្នាំប្រពៃណីចិនបានឆ្លុះបញ្ចាំងឱ្យឃើញពីការប្រែប្រួលមុខមាត់នៃសង្គមចិន គឺសេដ្ឋកិច្ចដែលកាន់តែមានកម្លាំងរស់រវើកជម្រើសកាន់តែសម្បូរបែបសង្វាក់ការរស់នៅកាន់តែលឿននិងទស្សនទានដែលកំពុងផ្លាស់ប្តូរៗលៗ។ ប៉ុន្តែទោះជាមានការផ្លាស់ប្តូរយ៉ាងណាក៏ដោយ មនោសញ្ចេតនាដ៏ជ្រាលជ្រៅអត្ថន័យជួបជុំគ្នានិងការជូនពរដ៏ល្អបវរដែលបង្កប់នៅក្នុងបុណ្យប្រពៃណីនេះមិនដែលមានការប្រែប្រួលសោះឡើយ ។ បុណ្យចូលឆ្នាំប្រពៃណីចិនបានក្លាយទៅជាបុណ្យអន្តរជាតិមួយដែលត្រូវគេរួមគ្នាអបអរសាទរនៅប្រទេសដ៏ច្រើន។ ឆ្លៀតឱកាសនេះកាសែត"ខេត្តយូនណានប្រទេសចិន"សូមជូនពរឱ្យមិត្តអ្នកអានគ្រប់រូបមានភាពសប្បាយរីករាយក្នុងបុណ្យចូលឆ្នាំប្រពៃណីចិន ៕

ទិដ្ឋភាពប្លែកពិសេសនៃខេត្តយូនណាន

មនុស្សរាប់ម៉ឺន នាក់រាំរាំជាមួយគ្នា (ដោយ ជ្វី ពីនយ៉ុង)

ខេត្តយូនណានជាកន្លែងមួយដែលមានជនជាតិដ៏ច្រើន ។ វប្បធម៌ដ៏ចម្រុះពណ៌បានធ្វើឱ្យខេត្តយូនណានមានទំនៀមទម្លាប់ឆ្លងបុណ្យចូលឆ្នាំប្រពៃណីចិនដែលមានលក្ខណៈពិពិធកម្ម។ ប្រជាជនជនជាតិផ្សេងៗទទួលស្វាគមន៍បុណ្យចូលឆ្នាំប្រពៃណីចិនតាមវិធីគ្រប់ប្រភេទ ។ យើងខ្ញុំសូមចែករំលែកគ្នាជាមួយលោកអ្នកអំពីបរិយាកាសសប្បាយរីករាយរបស់ជនជាតិភាគតិចខេត្តយូនណានក្នុងបុណ្យចូលឆ្នាំប្រពៃណីចិន ៕

★មនុស្សរាប់ម៉ឺននាក់រាំរាំជាមួយគ្នា

ក្នុងភាសាជនជាតិជីងភួពាក្យថា"មូណាវជុងកឺ"មានន័យថារាំរាំជាមួយគ្នា ។ ប្រជាជនជនជាតិជីងភួចូលចិត្តអបអរសាទរបុណ្យចូលឆ្នាំថ្មីតាមរយៈការច្រៀងចម្រៀងនិងរាំរាំជាមួយគ្នា ។ បុរសជនជាតិជីងភួវាយស្គរឈើដែលបញ្ចេញសំឡេង "តុង តុង តុង"ដែលបានបើកសម្ពោធនូវទិវាមូណាវជុងកឺ ។ អ្នករាំរាំនាំគេ ២នាក់កាន់កាំបិតវែងក្នុងដៃពាក់មួកវាងបក្សីហើយដើរនៅមុខអ្នករាំផ្សេងទៀត ។ នៅក្រោយអ្នករាំរាំ ២នាក់នោះ ប្រជាជនជនជាតិជីងភួដែលបានស្លៀកពាក់សម្លៀកបំពាក់ដ៏ស្រស់ស្អាតចាប់ដៃគ្នានិងដើរចូលទៅទីធ្លាដើម្បីរាំរាំជាមួយគ្នានិងបានបង្កើតជាក្បួនរាំរាប់ម៉ឺននាក់ ៕

★ក្មេងចាស់ប្រុសស្រីរួមគ្នាមុជទឹកក្តៅផុសពីក្រោមដី

ក្នុងចន្លោះពីថ្ងៃទី១ ដល់ទី ៣ ខែ១តាមចន្ទគតិចិនចំពេលផ្កាយជីរកស្គុសស្គាយយ៉ាងស្រស់បំព្រងប្រជាជនជនជាតិលីស៊ូដែលរស់នៅក្នុងតំបន់ជ្រលងទន្លេន្ទូជាំងភាគខាងលិចខេត្តយូនណានតែងតែរួមគ្នាអបអរសាទរទិវាប្រពៃណីដ៏សំខាន់មួយ គឺទិវាមុជទឹក ។ ក្មេងចាស់ប្រុសស្រីនាំគ្នាធ្វើដំណើរពីតំបន់ផ្សេងៗទៅមុជទឹកក្តៅផុសពីក្រោមដី ។ ក្នុងស្រះទឹកក្តៅផុសពីក្រោមដីគេប្រលែងគ្នា ឬមើលភ្នំខ្ពស់នៅទីឆ្ងាយដែលអាចជួយបន្ធូរអារម្មណ៍របស់ខ្លួននិងមានភាពសប្បាយរីករាយ ។ ជនជាតិលីស៊ូជឿជាក់ថា ការមុជទឹកក្តៅផុសពីក្រោមដីក្នុងបុណ្យចូលឆ្នាំថ្មីអាចបំបាត់នូវភាពនឿយហត់និងកង្វល់ ដើម្បីទទួលស្វាគមន៍ការមកដល់នៃឆ្នាំថ្មី ។ ទំនៀមទម្លាប់នេះបានត្រូវទទួលបន្តរហូតដល់សព្វថ្ងៃនេះហើយបានក្លាយទៅជាសកម្មភាពអបអរឆ្នាំថ្មីដែលមានការចូលរួមពីទេសចរកាន់តែច្រើននិងអ្នកស្រុកក្នុងតំបន់ ៕

★ពិធីពេញវ័យដែលរៀបចំនៅពេលមានអាយុ១៣ឆ្នាំ

បើនិយាយចំពោះយុវជនយុវនារីជនជាតិភូមីដែលមានអាយុ១៣ឆ្នាំលើខ្ពង់រាបភាគពាយ័ព្យនៃខេត្តយូនណានបុណ្យចូលឆ្នាំថ្មីមានសារសំខាន់ណាស់ ។ ពីព្រោះនៅបុណ្យចូលឆ្នាំប្រពៃណីចិនគេត្រូវចូលរួមពិធីស្បៃកខោឬពិធីស្បៃកសំពត់ ។ នៅថ្ងៃដាច់ឆ្នាំក្មេងៗដែលគម្រប់អាយុ១៣ឆ្នាំ ត្រូវជួបជុំគ្នាដើម្បីរួមគ្នាអបអរសាទរការពេញវ័យនិងលាចាកពីកុមារភាពយ៉ាងសប្បាយរីករាយ ។ នៅពេលព្រលឹមគេត្រូវត្រឡប់ទៅផ្ទះវិញភ្លាមៗ ។ ក្មេងប្រុសនិងក្មេងស្រីត្រូវចូលរួមពិធីពេញវ័យដោយបែងចែកពីគ្នា ។ ពិធីពេញវ័យរបស់ក្មេងស្រីត្រូវគេហៅថា "ពិធីស្បៃកសំពត់"ដែលម្តាយធ្វើជាអធិបតីចំណែកពិធីពេញវ័យរបស់ក្មេងប្រុសត្រូវគេហៅថា "ពិធីស្បៃកខោ" ដែលមាធ្វើជាអធិបតី។ នៅពេលរៀបចំពិធីខាងលើឪពុកម្តាយត្រូវរៀបចំពិធីជប់ល្បែងដើម្បីទទួលស្វាគមន៍ញាតិមិត្តដែលមកចូលរួមក្នុងពិធីពេញវ័យរបស់កូនគេ ។ គេត្រូវជូនសម្ពន្ធ៍ងមួយចានសាច់មួយដុំបេះដូងនិងថ្លើមជ្រួកខ្លះឱ្យភ្ញៀវម្នាក់ៗដើម្បីបង្ហាញថា ភ្ញៀវទាំងអស់គ្នាជាញាតិមិត្តជិតស្និទ្ធរបស់គេ ហើយមានចិត្តថ្លើមតភ្ជាប់នឹងគ្នា ៕

"សុភមង្គលមកដល់" (ដោយ យ៉ាង ជឺង)